Australia Awards



# ផ្លាស់ប្តូរអនាគត
# លោកអ្នកជាមួយ
# អាហារូបករណ៍អូស្ត្រាលី

# អាហារូបករណ៍អូស្ត្រាលី

កម្មវិធីជំនួយអភិវឌ្ឍន៍របស់រដ្ឋាភិបាលអូស្ត្រាលីនៅកម្ពុជា មានគោលបំណងរួមចំណែកលើកកម្ពស់វិបុលភាព ស្ថិរភាព និងកាត់បន្ថយភាពក្រីក្រ និងពង្រឹងស្ថិរភាពនយោបាយនៅក្នុងប្រទេសនេះ។

អាហារូបករណ៍អូស្ត្រាលី ជាអាហារូបករណ៍អន្តរជាតិដ៏មានកិត្យានុភាព ដែលរដ្ឋាភិបាលអូស្ត្រាលី ផ្តល់ជូនដល់អ្នកដឹកនាំពិភពលោកជំនាន់ថ្មីដើម្បីការអភិវឌ្ឍ។ តាមរយៈការសិក្សា និងការស្រាវជ្រាវ និស្សិតជ័យលាភីអាហារូបករណ៍នេះនឹងមានឱកាសក្នុងការអភិវឌ្ឍជំនាញ និងចំណេះដឹងដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរ និងផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសអូស្ត្រាលីកាន់តែមានភាពយូរអង្វែងរវាងប្រជាជនក្នុងប្រទេសកម្ពុជាជាមួយប្រជាជនអូស្ត្រាលី។

បេក្ខជននឹងឆ្លងកាត់ការវាយតម្លៃលើគុណភាពវិជ្ជាជីវៈការងារ និងវិជ្ជាជីវៈផ្ទាល់ខ្លួន លក្ខណៈសម្បត្តិកម្រិតវប្បធម៌ ហើយចំណុចដ៏សំខាន់បំផុតនោះគឺសក្តានុពលរបស់ពួកគេក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមចំពោះការអភិវឌ្ឍនៅប្រទេសកម្ពុជា។

## កម្រិតសិក្សា

អាហារូបករណ៍អូស្ត្រាលី គឺជាអាហារូបករណ៍រយៈពេលវែង ដែលផ្តល់ជូនប្រជាជនកម្ពុជានូវឱកាសសិក្សាថ្នាក់ក្រោយឧត្តមសិក្សា នៅគ្រឹះស្ថានសិក្សាប្រទេសអូស្ត្រាលី៖

- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ តាមរយៈការសិក្សាតាមមុខវិជ្ជា (Coursework) និងស្រាវជ្រាវ (Research)
- ថ្នាក់បណ្ឌិត (PhD)

## តើខ្ញុំអាចសិក្សាមុខវិជ្ជាអ្វីខ្លះ ?

ដោយទទួលស្គាល់ពីបញ្ហាប្រឈមជាក់ស្តែងនានាលើការអភិវឌ្ឍ នៅគ្រប់វិស័យទាំងអស់ក្នុងប្រទេសកម្ពុជា យើងសូមលើកទឹកចិត្តឲ្យបេក្ខជនដែលសិក្សាគ្រប់ជំនាញទាំងអស់មកដាក់ពាក្យឱ្យបានគ្រប់ៗគ្នា។ ពាក្យស្នើសុំអាហារូបករណ៍ទាក់ទងទៅនឹងវគ្គសិក្សាពីការប្រែប្រួលអាកាសធាតុត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យស្នើសុំ។

បេក្ខជន គួរតែជ្រើសរើសវគ្គសិក្សា ដែលស្របតាមបទពិសោធន៍ លក្ខណៈសម្បត្តិរបស់ខ្លួន និងផ្តល់មូលហេតុសមស្របដោយបញ្ជាក់ថាវគ្គសិក្សានោះប្រាកដជានាំឲ្យមានការផ្លាស់ប្តូរក្នុងអាជីពការងារ ឬទិសដៅការងារនាពេលអនាគតរបស់ខ្លួនមែន។

សូមបញ្ជាក់ថា អាហារូបករណ៍នេះពុំមានសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងទូទៅ ដូចជាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច (Master of Business Administration) នោះទេ។

យើងសូមណែនាំឲ្យបេក្ខជនចូលមើលព័ត៌មានលម្អិតបន្ថែមនៅលើគេហទំព័ររបស់ Australia Awards Cambodia៖

www.australiaawardscambodia.org

## តើនរណាខ្លះអាចដាក់ពាក្យបាន ?

**ប្រជាជនកម្ពុជាមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ អាចដាក់ពាក្យសុំអាហារូបករណ៍អូស្ត្រាលី នេះបានគ្រប់ៗគ្នា។** ការដាក់ពាក្យមានលក្ខណៈបើកចំហ និងប្រកួតប្រជែង។

អាហារូបករណ៍អូស្ត្រាលី សូមស្វាគមន៍បេក្ខជនមកពីគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសកម្ពុជា រួមទាំងស្ថាប័នសាធារណៈ គ្រឹះស្ថានអប់រំ និងស្ថាប័នគោលនយោបាយ អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងវិស័យឯកជន។

ស្ត្រី ជនមានពិការភាព ប្រជាជនរស់នៅ និងធ្វើការនៅតាមបណ្តាខេត្តក្រៅពីទីក្រុងភ្នំពេញ ជនជាតិដើមភាគតិច ក្រុមជនជាតិភាគតិច ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា LGBTIQA+ និងក្រុមប្រជាជនងាយរងគ្រោះផ្សេងទៀត ក៏ត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងឲ្យដាក់ពាក្យស្នើសុំអាហារូបករណ៍នេះផងដែរ។ យើងក៏មានផ្តល់ជូននូវកម្មវិធីគាំទ្រដើម្បីជួយសម្រួលឲ្យបេក្ខជនទាំងនេះដើម្បីអាចចូលរួមដាក់ពាក្យសុំអាហារូបករណ៍នេះឲ្យស្មើភាពគ្នាផងដែរ។

*ក្របមុខ៖ ទូតសុឆន្ទៈអាហារូបករណ៍អូស្ត្រាលីឆ្នាំ២០២៧ លោកស្រី នួន មករា និងលោក ម៉ម វណ្ណារ៉ូ*

## អត្ថប្រយោជន៍នៃអាហារូបករណ៍អូស្ត្រាលី

អាហារូបករណ៍អូស្ត្រាលី ផ្តល់ជូនរយៈពេលសិក្សាអប្បបរមា ដែលចាំបាច់ដើម្បីឲ្យអ្នកទទួលអាហារូបករណ៍អាចបញ្ចប់ កម្មវិធីសិក្សា ដែលគ្រឹះស្ថានអប់រំអូស្ត្រាលីបានបញ្ជាក់ជូន រួមទាំងការបណ្តុះបណ្តាលត្រៀមផងដែរ។

អ្នកទទួលអាហារូបករណ៍នឹងទទួលបានការឧបត្ថម្ភ ដូចខាងក្រោម៖

- សំបុត្រយន្តហោះទៅមក
- ប្រាក់ឧបត្ថម្ភដែលបើកជូននៅពេលទៅដល់អូស្ត្រាលី
- ថ្លៃសិក្សាទាំងអស់
- ប្រាក់ឧបត្ថម្ភសម្រាប់ការចំណាយរស់នៅ
- កម្មវិធីសិក្សាណែនាំ
- ធានារ៉ាប់រងសុខភាព
- ជំនួយគាំទ្រទៅលើវគ្គសិក្សាបំប៉នបន្ថែម
- ប្រាក់ឧបត្ថម្ភសម្រាប់ការចុះបំពេញការងារកម្មសិក្សានៅតាមទីតាំងផ្ទាល់សម្រាប់និស្សិតផ្នែកស្រាវជ្រាវ និងនិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការសិក្សាតាមមុខវិជ្ជា (Coursework) ដែលចាំបាច់ត្រូវចុះបំពេញការងារកម្មសិក្សានៅទីតាំងផ្ទាល់ (fieldwork)

## កាលបរិច្ឆេទដាក់ពាក្យសម្រាប់ការសិក្សាប្រចាំឆ្នាំ នៅប្រទេសអូស្ត្រាលី

បើកនៅថ្ងៃទី១ ខែកុម្ភៈ និង
បិទនៅថ្ងៃទី ៣០ ខែមេសា ជារៀងរាល់ឆ្នាំ

**ពាក្យស្នើសុំ និង/ឬ ឯកសារគាំទ្រដែលទទួលបាន ក្រោយកាលបរិច្ឆេទឈប់ទទួលពាក្យ នឹងមិនត្រូវយកមកធ្វើការពិចារណាឡើយ។**

## លក្ខខណ្ឌសម្រាប់ការស្នើសុំអាហារូបករណ៍

បេក្ខជនដែលស្នើសុំអាហារូបករណ៍អូស្ត្រាលី ត្រូវបំពេញតាម លក្ខខណ្ឌសម្រាប់ការស្នើសុំអាហារូបករណ៍ទាំងអស់ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងសៀវភៅណែនាំគោលនយោបាយ អាហារូបករណ៍អូស្ត្រាលី ដែលមាននៅលើគេហទំព័រ៖ https://www.dfat.gov.au/about-us/publications/australia-awards-scholarships-policy-handbook

### លក្ខខណ្ឌជាក់លាក់សម្រាប់ការស្នើសុំអាហារូបករណ៍ នៅក្នុងប្រទេសកម្ពុជា

បន្ថែមពីលើលក្ខខណ្ឌស្នើសុំអាហារូបករណ៍នៅក្នុងសៀវភៅណែនាំគោលនយោបាយអាហារូបករណ៍អូស្ត្រាលីទាំងនេះ បេក្ខជនមកពីប្រទេសកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌបន្ថែម ដូចខាងក្រោម៖

- ជាពលរដ្ឋកម្ពុជា ដោយពុំមានសញ្ជាតិពីរ ឬសញ្ជាតិបន្ថែម
- ជាពលរដ្ឋរស់នៅក្នុងប្រទេសកម្ពុជា បានរយៈពេល 24ខែ មុនថ្ងៃដាក់ពាក្យសុំ (ឧ. ថ្ងៃឈប់ទទួលពាក្យសុំ) ដោយលើកលែងតែអវត្តមានរយៈពេលខ្លីពាក់ព័ន្ធនឹងការងារ ការអភិវឌ្ឍវិជ្ជាជីវៈ ឬថ្ងៃឈប់សម្រាក
- មានបទពិសោធន៍ធ្វើការងារពេញម៉ោងយ៉ាងតិច ២៤ ខែ (ឬការងារក្រៅម៉ោងដែលសមមូលគ្នា) គិតត្រឹមថ្ងៃផុតកំណត់ទទួលពាក្យ (ឧ. ថ្ងៃឈប់ទទួលពាក្យសុំ)[1]
- ស្នើសុំលិខិតបញ្ជាក់អំពីប្រវត្តិសិក្សាពីមុនទាំងអស់ ទាំងបានបញ្ចប់ក្តី ឬមិនបានបញ្ចប់ក្តី ឬទាំងនៅក្នុងប្រទេសកម្ពុជា ឬនៅប្រទេសផ្សេងទៀត។[2]
- ផ្តល់ឯកសារគាំទ្រដែលត្រូវការទាំងអស់៖ សូមមើលតារាងទី 1៖ ឯកសារគាំទ្រ

**លើសពីនេះទៀត បេក្ខជន ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការសិក្សាតាមមុខវិជ្ជា (Coursework) ត្រូវ៖**

- ចេះភាសាអង់គ្លេសស្ទាត់ជំនាញយ៉ាងហោចណាស់ក៏ត្រឹមកម្រិតដូចខាងក្រោម (អ្នកដាក់ពាក្យដែលចេះភាសាអង់គ្លេសស្ទាត់ជំនាញ នៅពេលដាក់ពាក្យមានឱកាសខ្ពស់)៖
  - លទ្ធផលប្រលង IELTS ទទួលបានពិន្ទុសរុបយ៉ាងតិច 6.0 ដោយពុំមានពិន្ទុជំនាញណាមួយក្រោម 5.5 ឬ

[1] មិនថាបទពិសោធន៍ការងារនោះមាននៅពេលណាក៏ដោយ។ ការងារហាត់ការមានប្រាក់ឈ្នួល ក៏ចាត់ទុកថាជាបទពិសោធន៍ការងារ/ការងារដែរ។ បទពិសោធន៍ការងារ អាចបូកបញ្ចូលនូវបទពិសោធន៍ការងារក្រៅម៉ោង និងពេញម៉ោង ដរាបណាគណនាចូលគ្នាទៅ ស្មើនឹងបទពិសោធន៍ការងារពេញម៉ោង (24 ខែ)។

[2] អាចផ្តល់អាទិភាពដល់បេក្ខជនដែលមិនទាន់មានបរិញ្ញាបត្រជាន់ខ្ពស់ពីប្រទេសក្រៅពីប្រទេសកម្ពុជា។

  - ពិន្ទុប្រលង TOEFL តាមអ៊ីនធឺណិតយ៉ាងតិច 60 ឬ
  - ពិន្ទុ PTE សរុបត្រឹម 50
- ទទួលបានលទ្ធផលតេស្តភាសាអង់គ្លេសទៅតាមលក្ខខណ្ឌអាហារូបករណ៍ប្រចាំឆ្នាំនីមួយៗ
- បំពេញលក្ខខណ្ឌតម្រូវចុះឈ្មោះចូលរៀនសម្រាប់សាកលវិទ្យាល័យដែលបេក្ខជនបានជ្រើសរើសបន្តការសិក្សា៖
  - ក្នុងករណីមួយចំនួនបេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រដែលមានតម្លៃស្មើនឹងសញ្ញាបត្រថ្នាក់បរិញ្ញាបត្រអូស្ត្រាលី ឬ
  - ក្នុងករណីពិសេសមួយចំនួនបេក្ខជនអាចបំពេញលក្ខខណ្ឌតម្រូវចុះឈ្មោះចូលរៀនដោយពុំមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ។ នៅក្នុងករណីនេះ បេក្ខជនត្រូវបង្ហាញលិខិតបញ្ជាក់សម្រាប់វគ្គសិក្សា និងសាកលវិទ្យាល័យដែលពួកគេជ្រើសរើស។ បេក្ខជនត្រូវភ្ជាប់លិខិតនេះ ជាផ្នែកមួយនៃពាក្យសុំអាហារូបករណ៍អូស្ត្រាលី។[3]

**លើសពីនេះទៀត បេក្ខជនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកស្រាវជ្រាវ និងថ្នាក់បណ្ឌិត ត្រូវ៖**

- ចេះភាសាអង់គ្លេសស្ទាត់ជំនាញ ដោយយ៉ាងតិចត្រូវមាន៖
  - លទ្ធផលប្រលង IELTS ដែលទទួលបានពិន្ទុសរុបយ៉ាងតិច 6.5 ដោយពុំមានពិន្ទុជំនាញណាមួយក្រោម 6.0 ឬ
  - ពិន្ទុប្រលងតេស្ត TOEFL តាមអ៊ីនធឺណិតសរុបយ៉ាងតិច 84 ដែលតេស្តជំនាញនីមួយៗ ត្រូវមានពិន្ទុយ៉ាងតិច 21 ពិន្ទុ ឬ
  - ពិន្ទុសរុបសម្រាប់តេស្ត PTE គឺ 58 ពិន្ទុដោយពិន្ទុជំនាញទំនាក់ទំនងមិនក្រោម 50 ឡើយ
  - ទទួលបានលទ្ធផលតេស្តភាសាអង់គ្លេសទៅតាមលក្ខខណ្ឌអាហារូបករណ៍ប្រចាំឆ្នាំនីមួយៗ
- ផ្តល់ភស្តុតាងបញ្ជាក់អំពីការឆ្លើយឆ្លងពេញលេញ ជាមួយសាស្ត្រាចារ្យដឹកនាំ ឬមហាវិទ្យាល័យដែលបានស្នើឡើងដោយបង្ហាញថាមានវឌ្ឍនភាពពិតប្រាកដនៅក្នុងដំណើរនៃការរៀបចំសរសេរនិក្ខេបបទក្នុងរយៈពេលណាមួយ និងទទួលបានការគាំទ្រជាគោលការណ៍ពីសាស្ត្រាចារ្យដឹកនាំ ឬមហាវិទ្យាល័យនោះសម្រាប់ប្រធានបទស្រាវជ្រាវដែលបេក្ខជនបានស្នើឡើង។

# មុនពេលដាក់ពាក្យ

## ការស្រាវជ្រាវវគ្គសិក្សានៅសាកលវិទ្យាល័យ

សូមចូលទៅកាន់ Commonwealth Register of Institutions and Courses for Overseas Students (CRICOS) ដើម្បីស្វែងរកព័ត៌មានពេញលេញអំពីសាកលវិទ្យាល័យអូស្ត្រាលីទាំងអស់ និងវគ្គសិក្សាដែលមានសម្រាប់និស្សិតអន្តរជាតិ។

សូមបេក្ខជនចូលទៅកាន់គេហទំព័រ CRICOS https://cricos.education.gov.au/ និងគេហទំព័ររបស់សាកលវិទ្យាល័យនីមួយៗដើម្បីស្រាវជ្រាវអំពីវគ្គសិក្សាដែលបានស្នើឡើង និងបញ្ជាក់៖

- ថាតើវគ្គសិក្សានោះមានសម្រាប់និស្សិតអន្តរជាតិដែរឬទេ
- ថាតើមានព័ត៌មានលម្អិតអំពីខ្លឹមសារ និងប្រធានបទនៃវគ្គសិក្សាឬទេ
- អំពីតម្រូវការភាសាអង់គ្លេសសម្រាប់វគ្គសិក្សាដែលបេក្ខជនជ្រើសរើស



*ទូតសុឆន្ទៈអាហារូបករណ៍អូស្ត្រាលីឆ្នាំ២០២៧ លោកស្រី នួន មករា បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគោលនយោបាយសាធារណៈ និងគ្រប់គ្រង មកពី University of Melbourne*

[3] បេក្ខជន ដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ មិនតម្រូវឱ្យផ្តល់លិខិតបញ្ជាក់ការផ្តល់ជូនអាហារូបករណ៍ (Letter of Offer) នោះទេ។

# ដំណើរការដាក់ពាក្យស្នើសុំ

## ការដាក់ពាក្យតាមអនឡាញ

ដាក់ពាក្យតាមអនឡាញ៖ https://oasis.dfat.gov.au

នៅពេលដាក់ពាក្យ បេក្ខជន ត្រូវតែភ្ជាប់ជាមួយនូវឯកសារគាំទ្រទាំងអស់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ការដាក់ពាក្យសុំអាហារូបករណ៍សម្រាប់ប្រទេសកម្ពុជាដូចមានចែងនៅក្នុងតារាងទី 1 (នៅទំព័រទី 07)។ ក្រុមការងារអាហារូបករណ៍ សូមណែនាំឲ្យបេក្ខជនបំពេញ និងដាក់ពាក្យតាមប្រព័ន្ធអនឡាញឲ្យបានមុនកាលបរិច្ឆេទឈប់ទទួលពាក្យ។ កម្មវិធីដាក់ពាក្យតាមអនឡាញ (OASIS) អាចនឹងមានអត្រាអ្នកប្រើប្រាស់ខ្ពស់បំផុតនៅថ្ងៃកៀកនឹងកាលបរិច្ឆេទឈប់ទទួលពាក្យ ជាហេតុធ្វើឲ្យបេក្ខជនអាចជួបប្រទះនឹងការយឺតយ៉ាវក្នុងការដាក់ពាក្យ។

### ជំហានទាំង 4 នៃការដាក់ពាក្យតាមអនឡាញ

#### ជំហានទី 1 ៖ ពិនិត្យលក្ខខណ្ឌអាហារូបករណ៍

លក្ខខណ្ឌលម្អិត មានរៀបរាប់នៅក្នុងផ្នែកលក្ខខណ្ឌតម្រូវ។ លក្ខខណ្ឌទាំងនេះ ត្រូវតែបំពេញតាម ដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងការដាក់ពាក្យ។

សូមពិនិត្យមើលលក្ខខណ្ឌទាំងនេះដោយយកចិត្តទុកដាក់ មុនពេលបន្តទៅជំហានបន្ទាប់។

#### ជំហានទី 2 ៖ បង្កើតគណនីដើម្បីចូលទៅកាន់ OASIS

ការដាក់ពាក្យតាមអនឡាញទាំងអស់ ត្រូវតែដាក់ទៅកាន់៖ https://oasis.dfat.gov.au

ឯកសារណែនាំអំពីការប្រើប្រាស់ OASIS សម្រាប់បេក្ខជន អាចទាញយកបានពីគេហទំព័រ OASIS។

#### ជំហានទី 3 ៖ បញ្ចូលទិន្នន័យដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំងអស់ ហើយភ្ជាប់ឯកសារគាំទ្រទាំងអស់របស់អ្នក ចូលទៅក្នុងគេហទំព័រ OASIS

នៅពេលឆ្លើយតបនឹងសំណួរនៅក្នុងពាក្យស្នើសុំ ត្រូវប្រាកដថាអ្នកពិតជាបានចំណាយពេលវេលាគិតគូរអំពីចម្លើយ និងពាក្យពេចន៍នីមួយៗឲ្យបានល្អិតល្អន់។

បេក្ខជន ត្រូវមានគំនិតច្បាស់លាស់អំពីរបៀបដែលខ្លួននឹងរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា នៅពេលពួកគេត្រលប់មកកាន់ប្រទេសខ្លួនវិញ។ បេក្ខជន ត្រូវបានលើកទឹកចិត្តឲ្យគិតគូរអំពីទំនាក់ទំនងរវាងគោលដៅសិក្សា ការងារ ការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

នៅពេលដាក់ពាក្យតាមប្រព័ន្ធអនឡាញ បេក្ខជនត្រូវភ្ជាប់ឯកសារគាំទ្រទាំងអស់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ប្រទេសកម្ពុជា។ សូមមើលតារាងទី1៖ សម្រាប់បញ្ជីឯកសារតម្រូវទាំងអស់ដែលអ្នកត្រូវភ្ជាប់ ផ្អែកលើវគ្គសិក្សាដែលអ្នកជ្រើសរើស។

ទំហំឯកសារអតិបរមា (ក្នុងមួយឯកសារ) សម្រាប់ការដាក់បញ្ចូលនៅគេហទំព័រ OASIS គឺ 2 MB។

ជំនួយមានផ្តល់ជូនទៅតាមការស្នើសុំសម្រាប់ជនមានពិការភាពដែលចាំបាច់ត្រូវការជំនួយ ដើម្បីដាក់ស្នើពាក្យសុំ និង/ឬឯកសារគាំទ្រ។

#### ជំហានទី 4 ៖ ពិនិត្យ និងដាក់ពាក្យសុំអាហារូបករណ៍មុនកាលបរិច្ឆេទឈប់ទទួលពាក្យ

មុនពេលដាក់ពាក្យស្នើសុំ សូមត្រលប់ទៅពិនិត្យឡើងវិញនូវព័ត៌មានដែលអ្នកបានបំពេញនៅក្នុងពាក្យសុំ ហើយភ្ជាប់ គ្រប់ឯកសារគាំទ្រទាំងអស់ចូលទៅក្នុងគេហទំព័រ OASIS។

សូមណែនាំឲ្យបេក្ខជនបំពេញ និងដាក់ពាក្យតាមអនឡាញឲ្យបានរួចរាល់មុនកាលបរិច្ឆេទឈប់ទទួលពាក្យ។ កម្មវិធីដាក់ពាក្យតាមអនឡាញ (OASIS) អាចនឹងមានអត្រាអ្នកប្រើប្រាស់ខ្ពស់បំផុតនៅថ្ងៃកៀកនឹងកាលបរិច្ឆេទឈប់ទទួលពាក្យ ជាហេតុធ្វើឲ្យបេក្ខជនអាចនឹងយឺតយ៉ាវក្នុងការដាក់ពាក្យ។

### កំណត់សម្គាល់សំខាន់៖

**ដើម្បីកាត់បន្ថយឧបសគ្គរាំងចំពោះស្ត្រី ជនមានពិការភាព អ្នកដែលមកពីតាមបណ្តាខេត្ត ជនជាតិដើមភាគតិច ក្រុមជនជាតិភាគតិច ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា LGBTIQA+ និងក្រុមងាយរងគ្រោះដើម្បីអាចបំពេញតាមលក្ខខណ្ឌតម្រូវភាសាអង់គ្លេសបាន។**

អាហារូបករណ៍អូស្ត្រាលី នឹងត្រូវផ្តល់ជូនស្របតាមលក្ខខណ្ឌតម្រូវតឹងរឹង និងតាមរយៈដំណើរការជ្រើសរើសផ្អែកលើភាពប្រកួតប្រជែងត្រឹមត្រូវ និងតម្លាភាព។ សម្រាប់ស្ត្រី ជនមានពិការភាព អ្នកមកពីតាមបណ្តាខេត្ត ជនជាតិដើមភាគតិច ក្រុមជនជាតិភាគតិច ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា LGBTIQA+ និងក្រុមងាយរងគ្រោះដទៃទៀត (ដែលយើងហៅកាត់ថាក្រុម "សមធម៌") យើងដឹងថាការបំពេញតាមលក្ខខណ្ឌអាហារូបករណ៍ ដូចជាភាសាអង់គ្លេស អាចនឹងជាឧបសគ្គក្នុងការដាក់ពាក្យស្នើសុំអាហារូបករណ៍។

ដើម្បីកាត់បន្ថយឧបសគ្គក្នុងការទទួលបានឱកាសនេះកម្មវិធីអាហារូបករណ៍អូស្ត្រាលី ផ្តល់នូវកម្មវិធីសមធម៌ (Equity Pathways Program) ដែលត្រូវបានរៀបចំឡើងដើម្បីគាំទ្រសមាជិកក្រុមសមធម៌ ដើម្បីទទួលបានឱកាសចូលរួមការបណ្តុះបណ្តាលភាសាប្រកបដោយគុណភាពខ្ពស់។ តាមរយៈការគាំទ្រពីកម្មវិធីសមធម៌ (Equity Pathways Program) បេក្ខជនអាហារូបករណ៍មានសមត្ថភាពដែលមកពីក្រុមសមធម៌ អាចមានឱកាសខិតខំប្រឹងប្រែងពង្រឹងជំនាញភាសាអង់គ្លេស និងបំពេញតាមលក្ខខណ្ឌនេះបានដើម្បីអាចដាក់ពាក្យស្នើសុំកម្មវិធីអាហារូបករណ៍អូស្ត្រាលី។

ប្រសិនបើអ្នកគិតថាអ្នកមិនទាន់មានសមត្ថភាពភាពគ្រប់គ្រាន់ក្នុងដាក់ពាក្យសុំអាហារូបករណ៍ដោយសារការប្រើប្រាស់ភាសាអង់គ្លេសរបស់អ្នកនៅមានកម្រិត និងមានបំណងស្វែងយល់អំពីការដាក់ពាក្យស្នើសុំពីកម្មវិធីសមធម៌ (Equity Pathways Program) សូមទាក់ទងមកកាន់ការិយាល័យកម្មវិធីអាហារូបករណ៍អូស្ត្រាលី Australia Awards Cambodia ដើម្បីទទួលបានព័ត៌មានបន្ថែម។

## ការដាក់ពាក្យដោយមិនប្រើប្រាស់ប្រព័ន្ធអនឡាញ

បេក្ខជនអាចទាញយកពាក្យសុំបានតាមរយៈ៖ www.australiaawardscambodia.org

ពាក្យស្នើសុំជាឯកសារក្រដាសដែលបានបំពេញ (រួមមានទាំងឯកសារគាំទ្រទាំងអស់ ដែលបំពេញតាមលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ប្រទេសកម្ពុជាដូចមានចែងនៅក្នុងតារាងទី 1 (នៅទំព័របន្ទាប់) ត្រូវតែប្រគល់ជូនដោយដៃផ្ទាល់ ឬផ្ញើទៅស្ថានទូតអូស្ត្រាលី អគារលេខ 16B ផ្លូវរដ្ឋសភា ទីក្រុងភ្នំពេញ ហើយត្រូវដាក់នៅមុនកាលបរិច្ឆេទឈប់ទទួលពាក្យ។



*ទូតសុឆន្ទៈអាហារូបករណ៍អូស្ត្រាលីឆ្នាំ២០២៧ លោកស្រី នួន មករា បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគោលនយោបាយសាធារណៈ និងគ្រប់គ្រង មកពី University of Melbourne និងលោក ម៉ម វណ្ណារ៉ូ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសហគ្រិនភាព និងនវានុវត្តន៍មកពី the Australian National University*

# ឯកសារគាំទ្រ

តារាងទី 1 (ខាងក្រោម) រៀបរាប់អំពីឯកសារដែល**ត្រូវតែ**ផ្តល់ជូនភ្ជាប់មកជាមួយពាក្យស្នើសុំ ដើម្បីឲ្យពាក្យស្នើសុំរបស់អ្នកអាចបំពេញតាមលក្ខខណ្ឌពេញលេញ។

**តារាងទី 1: ឯកសារគាំទ្រ**

| ឯកសារ | ប្រភេទឯកសារ |
|---|---|
| **បេក្ខជនទាំងអស់ ត្រូវតែផ្តល់** | |
| សញ្ញាបត្រសាកលវិទ្យាល័យ ផ្លូវការទាំងអស់ ដោយមានបកប្រែជាភាសាអង់គ្លេស | សញ្ញាបត្រ |
| ព្រឹត្តិបត្រពិន្ទុសាកលវិទ្យាល័យផ្លូវការ អំពីមុខវិជ្ជាដែលបានបញ្ចប់ និង មិនទាន់បានបញ្ចប់ ដោយមានបកប្រែជាភាសាអង់គ្លេស | ព្រឹត្តិបត្រពិន្ទុ |
| ឯកសារបញ្ជាក់អត្តសញ្ញាណ និងថ្ងៃខែឆ្នាំកំណើត ដោយមានបកប្រែជាភាសាអង់គ្លេស (ឧ.ទំព័រព័ត៌មានផ្ទាល់ខ្លួននៃលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត) | លិខិតបញ្ជាក់ភាពជាពលរដ្ឋ |
| ភស្តុតាង ឬលិខិតបញ្ជាក់ការងារពីនិយោជកពីមុន/ឬបច្ចុប្បន្ន ដែលបញ្ជាក់អំពីមុខតំណែង រយៈពេលបានបំពេញការងារ និងស្ថានភាពការងារពេញម៉ោង ឬក្រៅម៉ោង | លិខិតបញ្ជាក់ការងារចេញដោយនិយោជក/ក្រសួង(គំរូនេះមាននៅលើគេហទំព័រកម្មវិធីអាហារូបករណ៍អូស្ត្រាលីដែលមានរៀបរាប់លម្អិតអំពីព័ត៌មានដែលត្រូវការ) |
| ប្រវត្តិរូបសង្ខេប បេក្ខជន**ត្រូវតែ**ប្រើគំរូប្រវត្តិរូបសង្ខេប ដែលមាននៅលើគេហទំព័រ Australia Awards Cambodia | ប្រវត្តិរូបសង្ខេប (CV) |
| **លើសពីនេះ សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈសិក្សាមុខវិជ្ជា (COURSEWORK) ត្រូវតែផ្តល់៖** | |
| ភស្តុតាងបញ្ជាក់អំពីកម្រិតជំនាញភាសាអង់គ្លេសនៅពេលដាក់ពាក្យ៖<br>• លទ្ធផលប្រលងតេស្ត IELTS ទទួលបានពិន្ទុសរុបយ៉ាងហោចណាស់ 6.0 ដោយពុំមានពិន្ទុជំនាញណាមួយតិចជាង 5.5<br>• ពិន្ទុប្រលង TOEFL តាមអ៊ីនធឺណិតយ៉ាងតិច 60 ឬក៏<br>• ពិន្ទុ PTE សរុបត្រឹម 50 លទ្ធផលតេស្តភាសាអង់គ្លេសទៅតាមលក្ខខណ្ឌអាហារូបករណ៍ប្រចាំឆ្នាំនីមួយៗ<br>លទ្ធផលតេស្តភាសាអង់គ្លេសទៅតាមលក្ខខណ្ឌអាហារូបករណ៍ប្រចាំឆ្នាំនីមួយៗ។ | លទ្ធផលតេស្តភាសាអង់គ្លេសផ្លូវការ |

| ឯកសារ | ប្រភេទឯកសារ |
|---|---|
| **លើសពីនេះ បេក្ខជនរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការស្រាវជ្រាវ (RESEARCH) និងថ្នាក់បណ្ឌិត ត្រូវតែផ្តល់៖** | |
| របាយការណ៍ពីអ្នកធានាផ្នែកសិក្សា | របាយការណ៍ពីអ្នកធានាផ្នែកសិក្សា<br>(គំរូរបាយការណ៍ពីអ្នកធានាផ្នែកសិក្សាមាននៅលើគេហទំព័រ Australia Awards Cambodia) |
| ផ្តល់ភស្តុតាងបញ្ជាក់អំពីការឆ្លើយឆ្លងពេញលេញជាមួយសាស្ត្រាចារ្យ ឬមហាវិទ្យាល័យដែលបានស្នើឡើង ដោយបង្ហាញអំពីវឌ្ឍនភាពពិតប្រាកដអំពីការរៀបចំសរសេរនិក្ខេបបទក្នុងរយៈពេលណាមួយ និងទទួលបានការគាំទ្រជាគោលការណ៍សម្រាប់ប្រធានបទស្រាវជ្រាវដែលបានស្នើឡើង | ឯកសារផ្សេងៗ |
| ភស្តុតាងបញ្ជាក់អំពីកម្រិតជំនាញភាសាអង់គ្លេសនៅពេលដាក់ពាក្យ៖<br>• លទ្ធផលប្រលងតេស្ត IELTS ទទួលបានពិន្ទុសរុបយ៉ាងតិច 6.5 ដោយពុំមានពិន្ទុជំនាញណាមួយក្រោម 6.0 ឡើយ ឬ<br>• ពិន្ទុប្រលងតេស្ត TOEFL តាមអ៊ីនធឺណិតសរុបយ៉ាងតិច 84 ដោយមានពិន្ទុតេស្តនីមួយៗយ៉ាងតិច 21 ឬ<br>• ពិន្ទុសរុបសម្រាប់ PTE គឺ 58 ពិន្ទុ ដោយពិន្ទុជំនាញទំនាក់ទំនងមិនត្រូវទាបជាង 50 ពិន្ទុឡើយ<br>លទ្ធផលតេស្តទាំងនេះ ត្រូវទទួលបានទៅតាមលក្ខខណ្ឌអាហារូបករណ៍ជាប្រចាំឆ្នាំនីមួយៗ។ | លទ្ធផលតេស្តផ្លូវការ |

សូមបញ្ជាក់ថា ឯកសារជាភាសាខ្មែរ ឬភាសាផ្សេងៗត្រូវបកប្រែទៅជាភាសាអង់គ្លេស។ នៅពេលដាក់ពាក្យស្នើសុំ រាល់ឯកសារបកប្រែ មិនចាំបាច់មានការបញ្ជាក់ជាផ្លូវការនោះទេ។ ម្យ៉ាងវិញទៀត ការបកប្រែដោយខ្លួនឯង ក៏អាចទទួលយកបានដែរ។

**ប្រសិនបើឯកសារគាំទ្រពាក់ព័ន្ធ មិនត្រូវបានផ្តល់ជូនដូចបានបញ្ជាក់ខាងដើមទេ នោះពាក្យស្នើសុំ នឹងត្រូវចាត់ទុកថាមិនមានលក្ខណៈសមស្រប និងមិនអាចទទួលយកបានទេ។**

កម្មវិធីអាហារូបករណ៍អូស្ត្រាលី Australia Awards Cambodia ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ដែលមិនអត់ឱនចំពោះសកម្មភាព ឬឥរិយាបថក្លែងបន្លំណាមួយឡើយ។ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលីបានកំណត់និយមន័យនៃអំពីការគៃបន្លំថាជាការទទួលបានអត្ថប្រយោជន៍ដោយមិនស្មោះត្រង់ ឬបង្កឲ្យមានការខាតបង់តាមរយៈការឆបោក ឬមធ្យោបាយផ្សេងៗ។ ឧទាហរណ៍ ការផ្តល់ព័ត៌មានក្លែងក្លាយ ឬការបំភាន់ ឬការមិនផ្តល់ព័ត៌មានពាក់ព័ន្ធ ក៏អាចចាត់ទុកថាជាការគៃបន្លំដែរ។ សកម្មភាពទាំងនេះ **អាចរាប់បញ្ចូលទាំងការមិនបានប្រកាសអំពីការសិក្សាពីមុន មិនថាបានបញ្ចប់ ឬមិនបានបញ្ចប់ក្តី**។

ប្រសិនបើរកឃើញមានការគៃបន្លំ ពាក្យស្នើសុំនោះនឹងត្រូវចាត់ទុកថាជាអសារបង់ ហើយបេក្ខជននឹងត្រូវហាមឃាត់មិនឲ្យដាក់ពាក្យស្នើសុំអាហារូបករណ៍ជារៀងរហូត។

## ដំណើរការជ្រើសរើស

នៅពេលឈប់ទទួលពាក្យ ពាក្យស្នើសុំទាំងអស់ នឹងឆ្លងកាត់ដំណើរការវាយតម្លៃ និងសម្រិតសម្រាំង។ ដំណើរការជ្រើសរើសនេះ ធ្វើឡើងដោយផ្អែកលើគោលការណ៍នៃភាពត្រឹមត្រូវ និងសមធម៌ ព្រមទាំងត្រូវឆ្លងកាត់សម្ភាសន៍ផងដែរ។ បេក្ខជនត្រូវឆ្លងកាត់ការវាយតម្លៃស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- សមត្ថភាពផ្នែកសិក្សា
- លទ្ធផលសក្តានុពល រួមទាំងការចូលរួមចំណែកដល់លទ្ធផលអភិវឌ្ឍន៍នៅកម្ពុជាដែរ
- ភាពជាអ្នកដឹកនាំវិជ្ជាជីវៈ និងផ្ទាល់ខ្លួន រួមទាំងបទពិសោធន៍ការងារពាក់ព័ន្ធ

## តើត្រូវធ្វើដូចម្តេចដើម្បីដឹងថាខ្ញុំត្រូវបានជ្រើសរើស ?

បេក្ខជននឹងទទួលបានព័ត៌មាននៅតាមដំណាក់កាលនៃការជ្រើសរើសនីមួយៗ ប្រសិនបើពាក្យស្នើសុំរបស់ពួកគេមិនបានឆ្លងទៅដំណាក់កាលបន្ទាប់ទេនោះ។

បេក្ខជនដែលបានសម្ភាសន៍រួចនឹងទទួលបានការជូនដំណឹងអំពីលទ្ធផលបន្ទាប់ពីដំណើរការជ្រើសរើសបានបញ្ចប់ភ្លាម។

### លក្ខខណ្ឌពិសេសដែលអនុវត្តចំពោះកម្មវិធីអាហារូបករណ៍អូស្ត្រាលី

សូមបញ្ជាក់ថាអាហារូបករណ៍អូស្ត្រាលី (Australia Awards Scholarships) ត្រូវផ្តល់ជូនជាបណ្តោះអាសន្នសិន រហូតទាល់តែបេក្ខជនបំពេញតាមលក្ខខណ្ឌខាងក្រោម៖

- បេក្ខជនទទួលបានកម្រិតភាសាអង់គ្លេសអប្បបរមាដូចខាងក្រោម៖
  - ពិន្ទុតេស្ត IELTS សរុបយ៉ាងតិច 6.5 ដោយពុំមានពិន្ទុជំនាញណាមួយក្រោម 6.0 ឡើយ
  - ពិន្ទុប្រលង TOEFL តាមអ៊ីនធឺណិតសរុបយ៉ាងតិច 84 ដែលតេស្តនីមួយៗ ត្រូវមានពិន្ទុយ៉ាងតិច 21 ឬពិន្ទុ PTE សរុប គឺ 58 ពិន្ទុ ហើយពិន្ទុជំនាញទំនាក់ទំនងមិនត្រូវទាបជាង 50 ពិន្ទុឡើយ។

ទោះបីជាសាកលវិទ្យាល័យដែលបេក្ខជនបានជ្រើសរើសនោះតម្រូវឲ្យមានកម្រិតពិន្ទុភាសាអង់គ្លេសទាបជាងនេះក្តី។ បន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាលភាសាអង់គ្លេស ប្រសិនបើបេក្ខជន មិនអាចទទួលបានពិន្ទុភាសាអង់គ្លេសស្របតាមកម្រិតដែលបានរៀបរាប់ខាងលើនេះទេ នោះអាហារូបករណ៍អូស្ត្រាលីបណ្តោះអាសន្ន នឹងទុកជាមោឃៈ។ បេក្ខជននឹងមិនអាចបន្តទទួលបានអាហារូបករណ៍ទៅសិក្សានៅក្នុងប្រទេសអូស្ត្រាលីបានឡើយ។

- បេក្ខជនត្រូវបានទទួលឲ្យចូលរៀននៅសាកលវិទ្យាល័យអូស្ត្រាលី ហើយនិង
- បេក្ខជនទទួលបានទិដ្ឋាការពាក់ព័ន្ធពីស្ថាប័នអន្តោប្រវេសន៍នៃប្រទេសអូស្ត្រាលី



*© រូបភាពរក្សាសិទ្ធិដោយ សេង ច័ន្ទសិរីពេជ្រ*

និស្សិតជ័យលាភី ត្រូវចុះកិច្ចសន្យាជាមួយ Commonwealth of Australia ដើម្បីទទួលយកលក្ខខណ្ឌអាហារូបករណ៍។ លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌផ្សេងៗនៃអាហារូបករណ៍នៅកម្ពុជា (Australia Awards Cambodia) នេះគឺថា និស្សិតជ័យលាភីអាហារូបករណ៍ ត្រូវត្រលប់មកប្រទេសកម្ពុជាវិញ និងស្នាក់នៅកម្ពុជាឲ្យបានយ៉ាងតិចពីរឆ្នាំ។ កម្មវិធីនេះរំពឹងថា អ្នកទទួលអាហារូបករណ៍ ត្រូវតែត្រលប់មកប្រទេសកម្ពុជាវិញ ដើម្បីប្រើប្រាស់ជំនាញ និងចំណេះដឹងដែលខ្លួនទទួលបានតាមរយៈកម្មវិធីអាហារូបករណ៍នេះសម្រាប់ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា។

បញ្ជីពេញលេញអំពីលក្ខខណ្ឌអាហារូបករណ៍ទាំងនេះ មាននៅក្នុងសៀវភៅណែនាំគោលនយោបាយអាហារូបករណ៍អូស្ត្រាលី នៅលើគេហទំព័រ៖

https://www.dfat.gov.au/about-us/publications/australia-awards-scholarships-policy-handbook

រដ្ឋាភិបាលអូស្ត្រាលី មិនផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬការគាំទ្រផ្សេងៗសម្រាប់អ្នកនៅក្នុងបន្ទុករបស់និស្សិតជ័យលាភីអាហារូបករណ៍ ដែលរួមដំណើរទៅកាន់ប្រទេសអូស្ត្រាលីជាមួយឡើយ។ និស្សិតជ័យលាភីអាហារូបករណ៍អូស្ត្រាលី ត្រូវទទួលខុសត្រូវលើការចំណាយផ្សេងៗ សម្រាប់សមាជិកគ្រួសាររបស់ខ្លួនក្នុងអំឡុងពេលរស់នៅប្រទេសអូស្ត្រាលី។

## ការបណ្តុះបណ្តាលមុនពេលចេញដំណើរ

មុនពេលចេញដំណើរទៅកាន់ប្រទេសអូស្ត្រាលី និស្សិតជ័យលាភីអាហារូបករណ៍អូស្ត្រាលីបណ្តោះអាសន្នទាំងអស់ ត្រូវចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោងរយៈពេលប្រហែលបីសប្តាហ៍មុនពេលចេញដំណើរ។




© រូបភាពរក្សាសិទ្ធិដោយ សេង ច័ន្ទសិរីពេជ្រ

បេក្ខជនទទួលអាហារូបករណ៍បណ្តោះអាសន្ន ដែលមិនទាន់ទទួលបានពិន្ទុភាសាអង់គ្លេសស្របតាមកម្រិតដែលបានកំណត់ ចាំបាច់ត្រូវចូលរៀនវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសពេញម៉ោងរយៈពេលប្រាំមួយខែ ដើម្បីអាចបំពេញទៅតាមលក្ខខណ្ឌតម្រូវភាសាអង់គ្លេស។

ក្នុងអំឡុងពេលនោះ បេក្ខជនដែលមានទីលំនៅស្នាក់អាស្រ័យនៅទីក្រុងភ្នំពេញ នឹងត្រូវបានផ្តល់ជូនជាប្រាក់អាហារូបករណ៍ជាប្រចាំខែ តួយ៉ាងបេក្ខជនបម្រើការងារនៅស្ថាប័នក្រៅរដ្ឋាភិបាលនឹងទទួលបានប្រាក់អាហារូបករណ៍ប្រចាំខែចំនួន 270 ដុល្លារអាមេរិកក្នុងមួយខែ និងបេក្ខជនបម្រើការងារនៅក្នុងស្ថាប័នរដ្ឋាភិបាល នឹងទទួលបានប្រាក់ខែចំនួន 210 ដុល្លារអាមេរិក។ សម្រាប់បេក្ខជនដែលស្នាក់អាស្រ័យនៅក្រៅទីក្រុងភ្នំពេញ និងជាអ្នកបម្រើការនៅស្ថាប័នក្រៅរដ្ឋាភិបាលនឹងទទួលបានប្រាក់ចំនួន 370 ដុល្លារអាមេរិកក្នុងមួយខែ និងប្រាក់ចំនួន 330 ដុល្លារអាមេរិកក្នុងមួយខែសម្រាប់អ្នកបម្រើការនៅស្ថាប័នរដ្ឋាភិបាល។

នៅពេលដាក់ពាក្យស្នើសុំ បេក្ខជន ត្រូវពិចារណាដោយយកចិត្តទុកដាក់ចំពោះស្ថានភាពហិរញ្ញវត្ថុដែលប៉ះពាល់បណ្តាលពីការតម្រូវឲ្យចូលរួមការបណ្តុះបណ្តាលភាសាអង់គ្លេសពេញម៉ោង និងទឹកប្រាក់អាហារូបករណ៍ដែលទទួលបាន។

## កាលបរិច្ឆេទសំខាន់ៗ

| | |
|---|---|
| **កម្មវិធីផ្សព្វផ្សាយអំពីអាហារូបករណ៍អូស្ត្រាលីនៅភ្នំពេញ និងតាមបណ្តាខេត្ត**<br>សូមតាមដានគេហទំព័រ និងបណ្តាញសង្គមរបស់យើងដើម្បីទទួលបានព័ត៌មានបច្ចុប្បន្នភាព | ខែធ្នូ ដល់ខែមេសា |
| **ការផ្សព្វផ្សាយព័ត៌មានអំពីអាហារូបករណ៍នៅភ្នំពេញនិងតាមបណ្តាខេត្ត និងតាមបណ្តាញសង្គម** | ខែមករា ដល់ខែមេសា |
| **ការដាក់ពាក្យស្នើសុំអាហារូបករណ៍ចាប់ផ្តើមបើក** | ថ្ងៃទី១ ខែកុម្ភៈ |
| **ឈប់ទទួលពាក្យស្នើសុំអាហារូបករណ៍** | ចុងខែមេសា |
| **ជូនដំណឹងបេក្ខជនថាត្រូវបានជ្រើសរើសសម្រាប់សម្ភាសន៍** | ខែមិថុនា (អាចមានការផ្លាស់ប្តូរ) |
| **សម្ភាសន៍បេក្ខជន** | ខែកក្កដា (អាចមានការផ្លាស់ប្តូរ) |
| **ជូនដំណឹងអំពីបេក្ខជនជ័យលាភីអាហារូបករណ៍ ( បេក្ខជនទទួលបានអាហារូបករណ៍បណ្តោះអាសន្ន )** | ខែសីហា/កញ្ញា (អាចមានការផ្លាស់ប្តូរ) |

## កំហុសទូទៅដែលអ្នកដាក់ពាក្យអាហារូបករណ៍តែងតែបានធ្វើ

- មិនបានភ្ជាប់នូវព្រឹត្តិបត្រពិន្ទុសាកលវិទ្យាល័យផ្លូវការសម្រាប់ការសិក្សាទាំងអស់ដែលបេក្ខជនបានបញ្ចប់ ឬមិនទាន់បានបញ្ចប់
- មិនបានភ្ជាប់សញ្ញាបត្រសាកលវិទ្យាល័យ
- មិនបានផ្ដល់នូវប្រវត្តិរូបសង្ខេបដោយប្រើគំរូផ្ដល់ឱ្យនៅលើគេហទំព័រ Australia Awards Cambodia
- មិនបានផ្ដល់នូវភស្តុតាង ឬរបាយការណ៍គ្រប់គ្រាន់ដែលបញ្ជាក់អំពីបទពិសោធន៍ការងាររយៈពេល២៤ខែ
- មិនបានផ្ដល់នូវលទ្ធផលតេស្តភាសាអង់គ្លេស ឬផ្ដល់នូវលទ្ធផលតេស្តទាបជាងកម្រិតដែលបានកំណត់

ការិយាល័យ៖ មជ្ឈមណ្ឌល PGCT ជាន់ទី 2
មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ

ទូរសព្ទ៖ +855 12 635 306 ឬ 15 391 127
អ៊ីមែល៖ info@australiaawardscambodia.org
គេហទំព័រ៖ www.australiaawardscambodia.org
Facebook: https://www.facebook.com/Australia.Awards.Kh/
Telegram: https://t.me/australiaawardscambodia

ព័ត៌មានបន្ថែម

ព័តមានអំពី Australia Awards Cambodia អាចរកបាននៅលើគេហទំព័រ www.australiaawardscambodia.org

ព័ត៌មានទូទៅបន្ថែមអំពីអាហារូបករណ៍អូស្ត្រាលី កម្មវិធីជំនួយអូស្ត្រាលី និងការសិក្សានៅប្រទេសអូស្ត្រាលី អាចរកបាននៅតាមតំណភ្ជាប់ខាងក្រោម៖

- https://www.dfat.gov.au/people-to-people/australia-awards
- https://www.studyaustralia.gov.au/

ព័ត៌មានអំពីទិដ្ឋាការ សិទ្ធិទទួលបាន និងលក្ខខណ្ឌទទួលបានអាហារូបករណ៍អូស្ត្រាលី អាចរកបាននៅក្នុង *កូនសៀវភៅណែនាំគោលនយោបាយ Australia Awards Cambodia*

នៅលើគេហទំព័រ៖
https://www.dfat.gov.au/about-us/publications/australia-awardsscholarships-policy-handbook

## អាហារូបករណ៍អូស្ត្រាលីសម្រាប់កិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់ទន្លេមេគង្គ

ចាប់ពីឆ្នាំ២០២៦ គម្រោងអាហារូបករណ៍អូស្ត្រាលីនឹងផ្ដល់ជូននូវអាហារូបរណ៍បន្ថែមសម្រាប់ប្រទេសកម្ពុជា តាមរយៈមូលនិធិកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់ទន្លេមេគង្គ។សម្រាប់ព័ត៌មានបន្ថែមអំពីអាហារូបករណ៍នេះសូមចូលទៅកាន់តំណភ្ជាប់មួយនេះ: Mekong-Australia Partnership (MAP)។

និស្សិតជ័យលាភីអាហារូបករណ៍នឹងទទួលបានអត្ថប្រយោជន៍ពិសេសដោយពួកគេអាចផ្សារភ្ជាប់បណ្ដាញទំនាក់ទំនងជាមួយនឹងថ្នាក់ដឹកនាំប្រទេសនៅក្នុងតំបន់ទន្លេមេគង្គ អាចចូលរួមសកម្មភាពវគ្គបណ្ដុះបណ្ដាលពង្រឹងសម្ថភាពអំឡុងពេលសិក្សាក្នុងប្រទេសអូស្ត្រាលី និងឱកាសអភិវឌ្ឍខ្លួនផ្សេងៗ ដែលអាចផ្សារភ្ជាប់ទំនាក់ទំនងរវាងនិស្សិតជ័យលាភីអាហារូបរណ៍កម្ពុជា ជាមួយនឹងនិស្សិតជ័យលាភីអាហារូបករណ៍មកពីប្រទេសក្នុងតំបន់ទន្លេមេគង្គ។សូមចូលទៅកាន់គេហទំព័រ Australia Awards Cambodia សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីដំណើរការដាក់ពាក្យ តាមរយៈតំណភ្ជាប់នេះ៖ AAS MAP។

Apply today
www.australiaawardscambodia.org

# ផែនទីសាកលវិទ្យាល័យប្រទេសអូស្ត្រាលី




**PLEASE NOTE:**

Only main campus locations have been indicated on map.
For more information on other campus locations visit:

www.studyinaustralia.gov.au